# របាយការណ៍សង្ខេប
# របស់ឯកឧត្តម ឈុន ឈន់ ប្រធានក្រុមប្រឹក្សាខេត្តកំពង់ធំ
# ស្តីពីវឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់ខេត្តកំពង់ធំ

ថ្ងៃព្រហស្បតិ៍ ៣រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ថ្ងៃទី២០ ខែមករា ឆ្នាំ២០២២

សូមគោរព!

- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

- សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី
- ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
- បងប្អូនអ្នកសារព័ត៌មាន និងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ជាបឋមក្នុងនាមរដ្ឋបាលខេត្ត និងក្នុងនាមខ្លួនខ្ញុំផ្ទាល់សូមថ្លែងអំណរគុណ ដែលអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលបានផ្តល់ឱកាសឲ្យ ខេត្តកំពង់ធំបានធ្វើបទបង្ហាញអំពីវឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅបន្តរបស់ខេត្តកំពង់ធំ។ ខ្ញុំក៏សូមយកឱកាសនេះ សម្តែងនូវសេចក្តីដឹងគុណចំពោះរាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏វាងវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលបានដាក់ចេញនូវគោលនយោបាយត្រឹមត្រូវ ក្នុងការបញ្ចៀសកម្ពុជាមិនឲ្យរងវិបត្តិធ្ងន់ធ្ងរនៃជំងឺកូវីដ១៩ និងអនុញ្ញាតឲ្យយើងទាំងអស់គ្នាមានឱកាសមកជួបជុំគ្នាផ្ទាល់ឡើងវិញនៅថ្ងៃនេះ។ ជាកិច្ចបន្ទាប់ ខ្ញុំបាទសូមរាយការណ៍ជូនដោយសង្ខេបនូវ ស្ថានភាពទូទៅ វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងសមិទ្ធផលសំខាន់ៗ របស់រដ្ឋបាលខេត្តកំពង់ធំដូចខាងក្រោមនេះ៖

## ១. ស្ថានភាពទូទៅ

–ខេត្តកំពង់ធំ ស្ថិតនៅកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ ១៦៨គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានព្រំប្រទល់ជាប់ខេត្តព្រះវិហារ ស្ទឹងត្រែង ក្រចេះ កំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ និងសៀមរាប **ចែកជាក្រុង០១ ស្រុក០៨ ឃុំ៧៣ សង្កាត់០៨ ភូមិ៧៦៧** ដែលមានប្រជាពលរដ្ឋចំនួន **១៧៧.៧២៨គ្រួសារ** ស្មើនឹង **៨២០.៩៦០នាក់ ស្រី៤១៧.០៣៨នាក់ ដង់ស៊ីតេប្រជាពលរដ្ឋ ៥៥នាក់/គ.ម$^{២}$**។ ខេត្តមានផ្ទៃដីសរុបចំនួន **១៥.០៦១គ.ម$^{២}$** ស្មើនឹង **១.៥០៦.១៩៧ហ.ត** ចែកជាពីរសណ្ឋានដីគឺ តំបន់ខាងក្រោមផ្លូវជាតិលេខ៦ ជាតំបន់វាលទំនាប លាតសន្ធឹងរហូតដល់មាត់បឹងទន្លេសាប អំណោយផលយ៉ាងខ្លាំងដល់ការដាំដុះស្រូវ និងការនេសាទ។ តំបន់ខាងលើផ្លូវជាតិលេខ៦ ជាតំបន់ខ្ពង់រាបសមប្រកបបំផុតសម្រាប់ដំណាំចម្ការដូចជាកៅស៊ូ ស្វាយចន្ទី និងដំឡូងមីជាដើម។

-តំបន់ដែលមានសក្តានុពលខាងវិស័យទេសចរណ៍មានដូចជា រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្រ្ត ប្រាសាទសំបូរព្រៃគុក ដែលត្រូវបានដាក់ចូលជាសម្បត្តិបេតិកភ័ណ្ឌពិភពលោក និងប្រាសាទគុហានគរ រមណីយដ្ឋានធម្មជាតិ និងសប្បនិម្មិតដូចជា ភ្នំសន្ទុក ស្ទឹងជីនិត ស្ទឹងព្រៃប្រស់ បឹងសំរិទ្ធ ជាដើមដែលភ្ញៀវទេសចរចូលចិត្តទៅទស្សនាកំសាន្តច្រើនជាងគេ។

-ខេត្តកំពង់ធំមានស្ទឹងចំនួន ០៤ គឺ ស្ទឹងសែន ស្ទឹងស្ទោង ស្ទឹងតាំងក្រសាំង និងស្ទឹងជីនិត។ លើសពីនេះទៀត ខេត្តមានផ្លូវជាតិសំខាន់ៗឆ្លងកាត់ចំនួន ០៥ខ្សែគឺ៖

- ផ្លូវជាតិលេខ៦ ប្រវែង **១៤៤គ.ម** ពីព្រំប្រទល់ខេត្តកំពង់ចាម ដល់ព្រំប្រទល់ខេត្តសៀមរាប
- ផ្លូវជាតិលេខ៦២ ប្រវែង **៣៦គ.ម** ពីទីប្រជុំជនខេត្ត ដល់ព្រំប្រទល់ខេត្តព្រះវិហារ
- ផ្លូវជាតិលេខ៧១ ប្រវែង **១៥គ.ម** ពីស្រុកបារាយណ៍ ដល់ព្រំប្រទល់ខេត្តកំពង់ចាម
- ផ្លូវជាតិលេខ៥០C ប្រវែង**១៩គ.ម** ពីភូមិត្រពាំងវែង ដល់ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
- ផ្លូវជាតិលេខ ៦០B ប្រវែង **៥២គ.ម** ពីទីប្រជុំជនឃុំកំពង់ថ្ម ដល់ខេត្តកំពង់ចាម។

## ២. ការងារក្រុមប្រឹក្សាខេត្ត

ផ្អែកតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវច្បាប់រៀបចំអង្គការ ដែលជាមូលដ្ឋានគតិយុត្តិសម្រាប់កិច្ចការកំណែទម្រង់រដ្ឋបាលតាមបែបប្រជាធិបតិយ្យនៅថ្នាក់ក្រោមជាតិ និងបានបង្កើតឲ្យមានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈការបោះឆ្នោតអសកល។

ខេត្តកំពង់ធំមានសមាជិកក្រុមប្រឹក្សាខេត្តចំនួន ២៥នាក់ សមាជិក្រុមប្រឹក្សាក្រុងស្រុក ចំនួន ១៦៩នាក់ និងសមាជិក្រុមប្រឹក្សាឃុំសង្កាត់ចំនួន ៥៧៧នាក់។ ក្នុងឆ្នាំ ២០២១ កន្លង ទៅនេះ ក្រុមប្រឹក្សាខេត្តបានបើកកិច្ចប្រជុំរបស់ខ្លួនបានចំនួន ៦៦លើក ក្នុងនោះប្រជុំសាមញ្ញ ១២លើក វិសាមញ្ញ ០៤លើក គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ១២លើក និងគណៈកម្មាធិការលទ្ធកម្ម ៣៨លើក។ ដោយសារតែវិបត្តិនៃជំងឺកូវីដ១៩ ក្រុមប្រឹក្សាបានអាក់ខានមិនបានរៀបចំវេទិកាសាធារណៈពិគ្រោះយោបល់របស់ខ្លួន ដើម្បីប្រមូលសំណើ សំណូមពរ និងកង្វល់របស់ប្រជាពលរដ្ឋនៅមូលដ្ឋានឡើង។

## ៣. សមិទ្ធផលសំខាន់ៗរបស់រដ្ឋបាលខេត្ត

វិស័យកសិកម្មជាវិស័យដែលចំបងក្នុងការរក្សាលំនឹងសេដ្ឋកិច្ចជូនប្រជាពលរដ្ឋ ក្នុងខេត្តកំពង់ធំ។ ក្នុងឆ្នាំ ២០២១ ផ្ទៃដីដាំដុះស្រូវមានសរុបចំនួន **៣០៦.៧២៥**ហ.ត ក្នុងនោះស្រូវប្រាំងសរុបចំនួន **៧៦.៩៥៦**ហ.ត និងស្រូវវស្សា ២២៩.៧៦៩ហ.ត។ ផ្ទៃដីប្រមូលផលសរុបចំនួន **៣០៥.៦១៦**ហ.ត ទិន្នផលជាមធ្យម **៣,១៩១**តោន ក្នុង១ហិកតា។ ជារួម តុល្យភាពស្បៀងប្រចាំឆ្នាំ២០២១ ក្រោយកាត់ទុក១៣%សម្រាប់ធ្វើពូជ ធ្វើចំណីសត្វ និងសម្រាប់តម្រូវការហូបចុកក្នុងខេត្ត។

ឆ្នាំ២០២១កន្លងទៅនេះ គឺជាឆ្នាំទី៣ នៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា។ ជាលទ្ធផល ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខ និងក្រោមការដឹកនាំរបស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋបាលខេត្ត ក៏

ដូចជាមន្ទីរ-អង្គភាព បានផ្តល់ និងបម្រើសេវាជូនប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព ក៏ដូចជាការអភិវឌ្ឍលើគ្រប់វិស័យដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងភូមិសាស្ត្រខេត្តកំពង់ធំ។ ដើម្បីរួមចំណែកក្នុងកិច្ចការអភិវឌ្ឍនេះ ក្នុងឆ្នាំ២០២១ ក្រុមប្រឹក្សាខេត្តកំពង់ធំបានអនុម័តគម្រោងវិនិយោគដែលប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្តបានចំនួន ១០គម្រោង និងបានទទួលការផ្តល់អនុលោមភាពពីក្រសួងមហាផ្ទៃ រួចរាល់ចំនួន ០៧គម្រោង។ ជាមួយគ្នានេះដែរ ក្រុមការងារជួយគាំទ្រឃុំសង្កាត់បានចុះសិក្សា និងជួយគាំទ្រដល់ដំណើរការនីតិវិធីលទ្ធកម្ម និងការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់បានចំនួន ៨១គម្រោងក្នុងនោះ បានប្រជុំដេញថ្លៃរួច ៧៥គម្រោង បានចុះកិច្ចសន្យាជាមួយអ្នកម៉ៅការរួច ៧៥គម្រោង។

រដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ បានរៀបចំបំពាក់ភ្លើងបំភ្លឺ និងអំពូល សឡាតាមដងផ្លូវ និងតាមសួនសាធារណៈចំនួន ៣.២៧៧គ្រឿង ភ្លើងសញ្ញាប្រុងប្រយ័ត្នតាមដងផ្លូវចំនួន ៥១គ្រឿង តម្លើងក្បាលពន្លត់អគ្គីភ័យចំនួន ១៩កន្លែង និងសាងសង់ភ្លើងស្តុបចំនួន ០២កន្លែង។ ក្រៅពីនេះដើម្បីរួមចំណែកក្នុងការកែលម្អសោភ័ណភាពតាមទីប្រជុំជនខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ សួនច្បារ និងកន្លែងសម្រាប់ប្រជាពលរដ្ឋសម្រាកកម្សាន្ត និងហាត់ប្រាណ ក៏ត្រូវបានកែលម្អ ពង្រីក និងសាងសង់ថ្មីចំនួន ១២កន្លែង ដែលក្នុងនោះ រួមមានការសាងសង់សំណង់ជំនឿសាសនាជាលក្ខណៈប្រវត្តិសាស្ត្រថ្មីៗ មួយចំនួនដូចជា វិមានឯករាជ្យ រូបសំណាកលោកតាក្រហមក រូបសំណាកអាចារ្យលាក់ រូបសំណាកដាវដែកកំពង់ស្វាយ និមិត្តសញ្ញាខេត្ត រូបសំណាកផែនទីក្រុងស្រុកទាំង៩ជាដើម។ រដ្ឋបាលខេត្តក៏សាងសង់ និងជួសជុលផ្លូវកៅស៊ូប្រភេទ DBST និងបេតុងអាមេចំនួន ១៣ខ្សែ ក្នុងក្រុងស្ទឹងសែន។

អនាម័យ បរិស្ថានក៏ត្រូវបានយកចិត្តដាក់ផងដែរ ដោយរដ្ឋបាល ខេត្តបានរៀបចំឲ្យមានទីលានចាក់សម្រាមចំនួន ០៩ទីតាំង ក្នុងក្រុងស្រុកទាំង០៩។ ទន្ទឹមនឹងនេះ រដ្ឋបាលខេត្តបាន និងកំពុងរៀបចំប្រព័ន្ធលូរំដោះទឹកភ្លៀង និងទឹកកខ្វក់ រួមទាំងប្រព្រឹត្តិកម្មទឹកកខ្វក់ និងអាងស្តុកសម្រាម ជាគម្រោងលើកកម្ពស់លំនៅដ្ឋានដែលជាប្រាក់កម្ចីរបស់ធនាគារអភិវឌ្ឍអាស៊ី(ADB) នៅក្នុងសង្កាត់ចំនួន ០៤ ក្នុងក្រុងស្ទឹងសែន សម្រេចបានលទ្ធផល ២៧,០៩% ដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២៣។

ការពង្រីកបណ្តាញអគ្គិសនីទទួលបានលទ្ធផលគួរជាទីមោទនៈ។ បើប្រៀបធៀបពីឆ្នាំ២០១៧ដែលជាឆ្នាំដំបូងនៃអាណត្តិក្រុមប្រឹក្សាឃុំសង្កាត់ និងឆ្នាំ២០២១ កន្លងទៅនេះ យើងឃើញថាមានការកើនឡើងពី ៧៥,៩៦% ទៅ ៩៦,៨៧% នៃភូមិចំនួន ៧៦៧ទូទាំងខេត្ត។

ការធ្វើកំណែទម្រង់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយ តម្លាភាព គណនេយ្យភាព និងបរិយាប័ន្ន ជាពិសេស ភាពងាយស្រួល មិនសាំញ៉ាំ ឆាប់រហ័ស តាមរយៈ យន្តការច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ពិតជាកំណែទម្រង់ដ៏ត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។ ដើម្បីបំពេញតម្រូវការ និងភាពងាយស្រួលក្នុងការគ្រប់គ្រង និងផ្តល់សេវា កាន់តែមានប្រសិទ្ធភាពជូនប្រជាពលរដ្ឋ រដ្ឋបាលខេត្តក៏បានសាងសង់អគារអង្គភាពច្រកចេញចូលតែមួយសាលាខេត្ត អគារការិយាល័យច្រកចេញចូលតែមួយក្រុងស្រុកចំនួន ០៤ស្រុកបានសាសង់រួចរាល់ និង០២ស្រុកកំពុងសាងសង់ និងបានសាងសង់អគាររដ្ឋបាលឃុំសង្កាត់ចំនួន ៧២លើ ៨១ឃុំសង្កាត់។ ក្នុងឆ្នាំ២០១៩ រដ្ឋបាលខេត្តក៏បានបង្កើតស្រុកចំនួន ០១ គឺស្រុកតាំងគោក ដែលបំបែកចេញពី ស្រុកបារាយណ៍ផងដែរ។ ក្នុងរយៈពេល១ឆ្នាំកន្លងទៅនេះ អង្គភាពច្រកចេញចូលតែមួយ

របស់រដ្ឋបាលខេត្តបានផ្តល់សេវាសរុបចំនួន ៦១.៤៧១សេវា សរុបជាទឹកប្រាក់ប្រមាណ ២.១៦៧លានរៀល។ ទន្ទឹមគ្នានេះ ការិយាល័យប្រជាពលរដ្ឋ ដែលជាតំណាងរបស់ប្រជាពលរដ្ឋដែលមានតួនាទីទទួល និង សម្រុះសម្រួលបណ្តឹងនៅក្រៅប្រព័ន្ធ តុលាការពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាល បានទទួលបណ្តឹងចំនួន ១២០បណ្តឹង ក្នុងនោះបានសម្រុះសម្រួលដោះស្រាយចំនួន ៦៣បណ្តឹង ធ្វើការស៊ើប អង្កេត ២៨បណ្តឹង បិទសំណុំរឿង ៥បណ្តឹង និងបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច ២៤បណ្តឹង។

កន្លងទៅថ្មីៗនេះ ដោយផ្អែកតាមអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាល និងតាមបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** រដ្ឋបាល ខេត្តកំពង់ធំបានចាត់ក្រុមការងារចុះត្រួតពិនិត្យ និងវាស់វែងទីតាំងអាស្រ័យផលដីព្រៃលិចទឹកតំបន់ជុំវិញបឹង ទន្លេសាប សរុបចំនួន ៥០.២៥៦,៣៧ហ.ត ស្មើនឹង ១.៦៤៨ក្បាលដី ក្នុងផ្ទៃ ដីទំហំ ១៤១.០៥៩ហ.ត ហើយ ប្រជាពលរដ្ឋដែលកំពុងអាស្រ័យផលក្នុងតំបន់៣ តាម ការស្រាវជ្រាវមានដីតំបន់៣ ចំនួន ២៨.៩៧០,៥៦ហ.ត ស្មើនឹង ៤.៨៥២គ្រួសារ ។ ប្រជាពលរដ្ឋចំនួន ២.៦៣៧គ្រួសារ បានប្រគល់ដីជូនរដ្ឋវិញ ដែលមានផ្ទៃដីទំហំសរុប ១២.៦៥៥,៨៥ហ.ត។ មកទល់ពេលនេះ រដ្ឋបាលខេត្តបានចុះស្តារដីព្រៃទន្រ្ទាន ដោយបានដាំដើមឈើ និងគ្រាប់ ត្នោតនៅលើខ្សែបន្ទាត់តំបន់៣ បានចំនួន ៤៤.៥៩១ដើម/គ្រាប់ ស្មើនឹងប្រវែង ៥១.៣២៦ម៉ែត្រ។ ក្រោយ ទទួលបទបញ្ជា រហូតមកថ្ងៃនេះ ខេត្តបានបង្ក្រាបបទល្មើសបានចំនួន ០៣ករណី ស្មើនឹងផ្ទៃដី ១២៣ហ.ត។

## ៤. ស្ថានភាពនៃការរីករាលនៃជំងឺកូវីដ១៩ និងការចាក់វ៉ាក់សាំង

គិតត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ ខេត្តកំពង់ធំ បានធ្វើតេស្តសំណាកចំនួន ៧៨.៦៨២សំណាក និង បានរកឃើញអ្នកវិជ្ជមានជំងឺកូវីដ១៩ ចំនួន ៦.៧០៩នាក់ ក្នុងនោះ បានព្យាបាលជាសះស្បើយចំនួន ៦.៤៣៥ នាក់ ស្លាប់ចំនួន ២៦៧នាក់ និងកំពុងសម្រាកព្យាបាល ចំនួន ៧នាក់។

កន្លងមក ជាការឆ្លើយតបទៅនឹងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងខេត្តកំពង់ធំ រដ្ឋបាលខេត្តបាន ដាក់នូវសេចក្តីណែនាំ ចំនួន០២ និងសេចក្តីសម្រេច ចំនួន២១ ព្រមទាំងលិខិតបទដ្ឋាន គតិយុត្តសំខាន់ៗជា ច្រើនទៀត។ ការដាក់ចេញឲ្យអនុវត្តវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ គឺសំដៅឈានទៅដល់ការកាត់ផ្តាច់ការឆ្លងរីករាលដាលក្នុងទ្រង់ទ្រាយធំ នៅក្នុងសហគមន៍ ដោយតម្រូវឲ្យអនុ វត្តនូវកាតព្វកិច្ចពាក់ម៉ាស់ និងរក្សាគម្លាតសុវត្ថិភាព រិតត្បិតការលក់ដូរ ការធ្វើដំណើរ ឬចរាចរណ៍ឆ្លងកាត់ កន្លែងកំពុងមានហានិភ័យខ្ពស់ ហាមឃាត់ការប្រមូលផ្តុំជួបជុំនានា និងហាមឃាត់ការប្រកបអាជីវកម្មណា ដែលងាយបណ្តាលឲ្យចម្លងជំងឺកូវីដ១៩។ លើសពីនេះទៀត រដ្ឋបាលខេត្តក៏បានធ្វើការណែនាំដល់រដ្ឋបាល ក្រុង-ស្រុក ចាត់វិធានការធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាព និងធ្វើការផាកពិន័យ ចំពោះជនទាំងឡាយណា ដែល ល្មើសនឹងបម្រាមនានា ដែលបានដាក់ចេញដោយរដ្ឋបាលខេត្ត។

ស្របតាមការដឹកនាំដ៏ខ្ពង់ខ្ពស់ និងប្រកបដោយចក្ខុវិស័យរបស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការដាក់ចេញនូវផែនការ ចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃនៅទូទាំងប្រទេស ខេត្តកំពង់ធំបានយក ចិត្តទុកដាក់ផ្តល់វ៉ាក់សាំងជូនប្រជាពលរដ្ឋអាយុលើស១៨ឆ្នាំ និងកុមារអាយុ៥ឆ្នាំដល់ក្រោម១៨ឆ្នាំដូចជា អ្នកទទួលបានវ៉ាក់សាំងលើកទី១ សរុបចំនួន ៦១៣.០៧៦នាក់ អ្នកទទួលបានវ៉ាក់សាំងលើកទី២ចំនួន

៤៣៨.០៩៣នាក់ អ្នកទទួលវ៉ាក់សាំងលើកទី៣ចំនួន ១០០.៦១០នាក់ និងដូសជំរុញលើកទី៤ ចាប់ពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២តទៅ។

## ៥. ទិសដៅអនុវត្តបន្ត

១.បន្តពង្រឹងការផ្តល់សេវាសាធារណៈតាមរយៈយន្តការច្រកចេញចូលតែមួយ និងបន្តរៀបចំសាងសង់អគារការិយាល័យច្រកចេញចូលតែមួយនៅតាមបណ្តាស្រុក ដែលមិនទាន់មាន។

២.ជួយគាំទ្រ និងបង្កើនសមត្ថភាពដល់រដ្ឋបាលក្រុង ស្រុក លើការងារគ្រប់គ្រងធនធាន មនុស្ស នៃរចនាសម្ព័ន្ធរដ្ឋបាលក្រុង/ស្រុក ដែលបានធ្វើសមាហរណកម្មឆ្នាំ២០២០។

៣.ណែនាំ និងពិនិត្យសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព គុណភាព សំណង់ និងផលប៉ះពាល់ផ្សេងៗ ក្នុងការជួសជុល និងកែសម្រួលបណ្តាសំណង់សាធារណៈ និងសំណង់បេតិកភ័ណ្ឌ។

៤.បន្តជំរុញការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក និងគ្រឿងញៀនឲ្យអស់ពីលទ្ធភាពតាមគោលការណ៍របស់គណៈបញ្ជាការ ដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្នាក់ខេត្ត ឲ្យមានប្រសិទ្ធភាព សំដៅកាត់បន្ថយគ្រោះថ្នាក់ចរាចរឲ្យស្ថិតនៅកម្រិតទាប។

៥.បន្តរៀបចំវេទិកាសាធារណៈដើម្បីប្រមូលនៅសំណើ សំណូមពរ និងកង្វល់របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

៦.បន្តជំរុញការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋទូទាំងខេត្ត។

៧.បន្តចុះវាស់វែង និងស្រង់ទិន្នន័យដីដែលប្រជាពលរដ្ឋបានប្រើប្រាស់ និងអាស្រ័យផលតំបន់៣ទាំងអស់។

៨.បន្តចុះដាំកូនឈើឡើងវិញក្នុងតំបន់ព្រៃលិចទឹកដែលបានដកហូត។

៩.ចាត់តាំងឲ្យមានក្រុមល្បាតដោយប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប និងវិធានការសរុប ដើម្បីការពារ និងបង្ក្រាបបទល្មើសនានា ដែលកើតក្នុង តំបន់ព្រៃលិចទឹកបឹងទន្លេសាបភូមិសាស្ត្រខេត្តកំពង់ធំ។

១០.ជំរុញការអនុវត្តលិខិតលេខ ៧០៥ ស.ជ.ណ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។